LONGBEACH COMMUNITY DEVELOPMENT

CITY OF LONG BEACH · CALIFORNIA · INCORPORATED 1897

# PUBLIC NOTICE

## សេចក្តីជូនដំណឹងអំពីសវនាការសាធារណៈ
## និងលទ្ធភាពមានផ្តល់ជូនឯកសារ

នៅថ្ងៃពុធ ទី 15 ខែមករា ឆ្នាំ 2025 វេលាម៉ោង 4:00 រសៀល Long Beach Community Investment Company (LBCIC, ក្រុមហ៊ុនវិនិយោគសហគមន៍នៃទីក្រុងឡុងប៊ិច) នឹងបើកសវនាការសាធារណៈមួយនៅ City Council Chambers (សភាក្រុមប្រឹក្សាទីក្រុង) ដែលស្ថិតក្នុងសាលាក្រុងឡុងប៊ិច ដែលមានអាសយដ្ឋាននៅ 411 West Ocean Blvd., Long Beach, CA 90802។

គោលបំណងនៃសវនាការសាធារណៈនេះគឺដើម្បីទទួលមតិរបស់សាធារណជនអំពីការកែប្រែមួយភាគធំលើផែនការសកម្មភាព FY 2024-2025 និងការកែប្រែមួយភាគធំសម្រាប់ផែនការសកម្មភាព FY 2022-2023។ ការកែប្រែមួយភាគធំនេះនឹងបែងចែកចំណូលនៃកម្មវិធី Neighborhood Stabilization Program (NSP, កម្មវិធីរក្សាស្ថិរភាពសង្កាត់) ចំពោះ Community Development Grant (CDBG, ថវិកាជំនួយអភិវឌ្ឍន៍សហគមន៍) សម្រាប់ Home Improvement Roof Grant Program (កម្មវិធីថវិកាជំនួយកែលម្អដំបូលគេហដ្ឋាន) ហើយនឹងបែងចែកឡើងវិញនូវថវិកា CDBG នៃ FY 2022-2023 ចំពោះ Home Improvement Roof Grant Program ដើម្បីបំពេញតម្រូវការជាអាទិភាពក្នុងផែនការបង្រួមចូលគ្នារយៈពេលប្រាំឆ្នាំ។

ចាប់ពីថ្ងៃទី 13 ខែធ្នូ ឆ្នាំ 2024 ច្បាប់ចម្លងនៃសេចក្តីព្រាងសម្រាប់ការកែប្រែមួយភាគធំលើផែនការសកម្មភាព FY 2024-2025 និង FY 2022-2023 នឹងមានផ្តល់ជូនសម្រាប់ការបញ្ចេញមតិ និងវាយតម្លៃជាសាធារណៈ។ Draft Amendment (សេចក្តីព្រាងនៃការកែប្រែ) នេះអាចទាញយកបានពីផ្នែក "Stay Informed: Latest News (បន្តទទួលបានព័ត៌មាន៖ ព័ត៌មានថ្មីបំផុត)" នៅទំព័រដើមនៃគេហទំព័ររបស់ Long Beach Community Development Department (នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍នៃទីក្រុងឡុងប៊ិច) longbeach.gov/lbcd ឬដោយមកផ្ទាល់នៅអាសយដ្ឋាន 411 W. Ocean Blvd., Long Beach, CA 90802 ឬទាក់ទងទៅ Elizabeth Weithers តាមអ៊ីមែល Elizabeth.Weithers@longbeach.gov ឬតាមទូរសព្ទលេខ (562) 570-6912។

ទីក្រុងឡុងប៊ិចមានបំណងផ្តល់ជូនការសម្របសម្រួលសមស្របសម្រាប់សវនាការសាធារណៈនេះ ដោយអនុវត្តតាម Americans with Disability Act (ADA, ច្បាប់ស្តីពីជនពិការអាមេរិក) ឆ្នាំ 1990។ ប្រសិនបើអ្នកត្រូវការការសម្របសម្រួលពិសេស ឬស្នើសុំឯកសារបកប្រែ សូមហៅទូរសព្ទទៅ Elizabeth Weithers តាមរយៈលេខ (562) 570-6912 យ៉ាងតិច 48 ម៉ោងមុនសវនាការសាធារណៈដែលប្រព្រឹត្តទៅនៅថ្ងៃទី 15 ខែមករា ឆ្នាំ 2025។ សម្រាប់មនុស្សដែលមានពិការភាពក្នុងការស្តាប់ឬនិយាយ សូមហៅទូរសព្ទទៅលេខ 711 ដើម្បីភ្ជាប់ជាមួយសេវាបញ្ជូនបន្តផ្នែកទូរគមនាគមន៍។ ពលរដ្ឋដែលចង់ផ្តល់មតិជាសំណេរត្រូវតែផ្តល់មតិត្រឹមថ្ងៃទី 13 ខែមករា ឆ្នាំ 2025 សម្រាប់សវនាការសាធារណៈដែលប្រព្រឹត្តទៅនៅថ្ងៃទី 15 ខែមករា ឆ្នាំ 2025។ មតិជាសំណេរក៏អាចផ្ញើទៅ Elizabeth Weithers នៃ Community Development Department ដែលមានអាសយដ្ឋាននៅ 411 W. Ocean Blvd., Long Beach, CA 90802 ឬដាក់បញ្ជូនតាមរយៈអ៊ីមែលទៅ Elizabeth.Weithers@longbeach.gov។

ដើម្បីស្នើសុំព័ត៌មាននេះជាទម្រង់ផ្សេងពីនេះ ឬស្នើសុំឱ្យមានការសម្របសម្រួលសមស្របណាមួយ សូមទាក់ទងទៅ Community Development Department តាមរយៈ longbeach.gov/lbcd និងទូរសព្ទលេខ 562.570.3807។ យើងស្នើសុំឱ្យអ្នកដាក់សំណើយ៉ាងតិចបីថ្ងៃនៃថ្ងៃធ្វើការ ដើម្បីធានាឱ្យមានការផ្តល់ជូនតាមសំណើ។ ទោះជាយ៉ាងនេះក្តី យើងនឹងព្យាយាមសម្របសម្រួលតាមសំណើដែលដាក់យឺតពេលជាងនេះ។